# អតីតឆ្មាំយាមគុកផ្តល់សក្ខីកម្មដ៏គ្រោះក្បាយទាក់ទិននឹង ដំណើរប្រតិបត្តិការរបស់គុកទួលស្លែង និងវាលពិឃាតបឹងជើងឯក

*ដោយ ឡូរ៉ា ម៉ាកដូណល់*

*ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*

*នៅក្នុងថ្ងៃនេះ ហ៊ឹម ហ៊ុយ អាយុ៥៤ឆ្នាំ បានវិលត្រឡប់មកបង្ហាញខ្លួនក្នុងនាមជាសាក្សីសារជាថ្មីម្តងទៀត ដោយផ្តល់សក្ខីកម្មយ៉ាងគ្រោះក្បាយស្តីពីដំណើរប្រតិបត្តិការរបស់គុកទួលស្លែង (មន្ទីរស-២១) និងវាលពិឃាតបឹងជើងឯក ដែលមន្ទីរឃុំឃាំងសម្ងាត់ទាំងពីរនេះត្រូវបានគ្រប់គ្រងដោយជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ ដោយសារតែ ឌុច នៅតែអះអាងថា គាត់មិនសូវដឹងពីដំណើរប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរឃុំឃាំងទាំងពីរនេះ ហើយចំណែកឯសាក្សីដែលជាអ្នកទោសក៏ត្រូវបានឃុំឃាំងនៅតែមួយកន្លែង ដូច្នេះការរៀបរាប់របស់ឆ្មាំយាមគុកម្នាក់នេះពិតជាមានសារសំខាន់ ដោយសារតែគាត់មានតួនាទីច្រើននៅតាមតំបន់ផ្សេងៗគ្នា ។ យ៉ាងណាមិញ ហ៊ឹម ហ៊ុយ នឹងបន្តធ្វើសក្ខីកម្មរបស់គាត់នៅថ្ងៃស្អែកបន្ថែមទៀតផងដែរ ។*

## *ហ៊ឹម ហ៊ុយ មិនអនុវត្តសិទ្ធិមិនធ្វើការឆ្លើយតបទេ ប៉ុន្តែមេធាវីរបស់គាត់បែរជានៅស្ងៀមពេញមួយថ្ងៃ*

*កាលពីម្សិលមិញ ហ៊ឹម ហ៊ុយ បានស្នើសុំពេលវេលាយ៉ាងយូរដើម្បីពិភាក្សាជាមួយនឹងមេធាវីរបស់គាត់ស្តីពីការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ។ ប៉ុន្តែ វាពិតជាគួរឲ្យចង់ដឹងថាតើហេតុអ្វីបានជាក្នុងអំឡុងរយៈពេលប្រាំមួយម៉ោងនៃការសួរសំណួរ ហ៊ឹម ហ៊ុយ មិនបានអនុវត្តសិទ្ធិមិនធ្វើការឆ្លើយតបរបស់គាត់ ហើយថែមទាំងបានសារភាពថាគាត់ធ្លាប់បានសម្លាប់មនុស្សយ៉ាងហោចណាស់ម្នាក់ នៅឯវាលពិឃាតបឹងជើងឯក ។ មេធាវីរបស់ ហ៊ឹម ហ៊ុយ ដែលត្រូវបានចាត់តាំងឲ្យមកធ្វើជាមេធាវីដោយអង្គភាពគាំទ្រអ្នកជំនាញ និងសាក្សីរបស់ អ.វ.ត.ក មិននិយាយស្តីអ្វីទាំងអស់ក្នុងអំឡុងដំណើរការនីតិវិធី បើទោះបីជាយើងមិនដឹងថាតើគាត់មានសិទ្ធិនិយាយក៏ដោយ ។ យោងតាម អង្គភាពកិច្ចការសាធារណៈរបស់ អ.វ.ត.ក មេធាវីមានតួនាទីណែនាំកូនក្តីរបស់ខ្លួនទាក់ទិននឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ជា*

ជាងមកធ្វើជាតំណាងឲ្យកូនក្តីតែមួយមុខ។ នាព្រឹកនេះ លោកប្រធានចៅក្រម និល ណុន បានសួរទៅកាន់ ហ៊ុម ហ៊ុយ ថា តើគាត់ចង់ឲ្យមេធាវីរបស់គាត់មានវត្តមាននៅក្នុងបន្ទប់សវនាការបន្តទៀត ឬក៏ចង់ឲ្យមេធាវីរង់ចាំនៅខាងក្រៅបន្ទប់សវនាការ។ ហ៊ឹម ហ៊ុយ បាននិយាយថាគាត់សូមឲ្យមេធាវីរបស់គាត់មានវត្តមាននៅក្នុងបន្ទប់សវនាការបន្តទៀត។ លោកប្រធានចៅក្រមបានប្រាប់ ហ៊ុម ហ៊ុយ ឲ្យធ្វើការពិភាក្សាយោបល់ជាមួយនឹងមេធាវីរបស់គាត់ទាក់ទិននឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ហើយបានបង្គាប់ឲ្យគាត់ធ្វើការឆ្លើយតបនឹងសំណួររបស់ចៅក្រមដោយខ្លួនឯងទាំងអស់។

## ដំណើរប្រតិបត្តិការខាងក្នុង និងជុំវិញមន្ទីរស-២១

ក្នុងឆ្នាំ១៩៧២ ឬ១៩៧៣ ហ៊ុម ហ៊ុយ ត្រូវបានបង្ខំឲ្យចូលបំរើកងទ័ព។ ក្រោយពីទទួលបានវគ្គហ្វឹកហ្វឺនធ្វើជាកងទ័ពរួចមក គាត់ក៏ត្រូវបានបញ្ជូនពីអង្គភាពមួយទៅអង្គភាពមួយទៀត។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គភាពរបស់ ហ៊ុម ហ៊ុយ បានចូលរួមជាមួយកងទ័ពខ្មែរក្រហម«វាយរំដោះ» ទីក្រុងភ្នំពេញ។ ក្រោយមកទៀត ហ៊ឹម ហ៊ុយ បានធ្វើការងារដកស្ទូងនៅតាមវាលស្រែជាមួយនឹងសមមិត្ត ហ៊ី ជាប្រធានរបស់ ឌុច ដែលជាអ្នកជ្រើសរើស ហ៊ឹម ហ៊ុយ ឲ្យមកបំរើការនៅមន្ទីរស-២១។

អង្គភាព«ផ្នែកការពារ»របស់ ហ៊ុម ហ៊ុយ មានទីតាំងនៅក្នុងអគារតូចមួយឋិតនៅប៉ែកខាងក្រៅបរិវេណមន្ទីរស-២១ ហើយអង្គភាពនេះមានតួនាទីយាមច្រកចូល និងទទួលអ្នកទោសដែលមកដល់។ អង្គភាពរបស់ ហ៊ុម ហ៊ុយ ក៏មានតួនាទីចាប់ខ្លួនអ្នកទោស ដឹកជញ្ជូនអ្នកទោសដែលចាប់ខ្លួនរួចហើយ និងនាំអ្នកទោសទៅកាន់វាលពិឃាតបឹងជើងឯកផងដែរ។ ប្រសិនបើមិនមានបញ្ជាឲ្យបំពេញកិច្ចការដែលរៀបរាប់ដូចខាងលើ នោះសមាជិកទាំងអស់របស់អង្គភាពនេះត្រូវចិញ្ចឹមសត្វ។ ហ៊ុម ហ៊ុយ គ្រាន់តែជាឆ្មាំយាមគុកធម្មតាម្នាក់តែប៉ុណ្ណោះ។ ប៉ុន្តែក្រោយមកគាត់ក៏ត្រូវបានតំឡើងតំណែងជាប្រធានអង្គភាពការពារនេះ បន្ទាប់ពីអ្នករួមការងារនៅក្នុងអង្គភាពជាមួយគ្នាជាច្រើននាក់បានបាត់ខ្លួន។ ក្នុងនាមជាប្រធានអង្គភាព ហ៊ុម ហ៊ុយ បានដើរល្បាតជុំវិញបរិវេណ និងតាមអគាររបស់មន្ទីរស-២១ ដើម្បីធានាថាឆ្មាំយាមគុកទាំងអស់បានបំពេញតួនាទីរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួន។

អង្គភាពរបស់ ហ៊ីម ហ៊ុយ ត្រូវបានទទួលបញ្ជាពី ឌុច តាមរយៈ ហ៊ា ឲ្យធ្វើការចាប់ខ្លួនមនុស្សនៅក្នុងទីក្រុងភ្នំពេញ ។ ហ៊ីម ហ៊ុយ តែងតែទៅផ្សារកណ្តាលនៅពេលយប់ដើម្បីចាប់ខ្មាំងដែលត្រូវបានបោកបញ្ឆោតដោយកងទ័ពខ្មែរក្រហមឲ្យមកកាន់ទីនេះ ។ ជាមួយគ្នានេះ អង្គភាពរបស់ ហ៊ីម ហ៊ុយ ក៏ត្រូវធ្វើដំណើរចុះទៅតាមជនបទ ដើម្បីដឹកជញ្ជូនអ្នកទោសដែលត្រូវបានចាប់ខ្លួនដោយអង្គភាពកងទ័ពតាមតំបន់ ឬដោយក្រសួងរដ្ឋាភិបាល ដើម្បីបញ្ជូនមកកាន់មន្ទីរស-២១ ។ ឌុច ធ្លាប់បានបញ្ជា ហ៊ីម ហ៊ុយ ឲ្យទៅដឹកជញ្ជូនទាហានវៀតណាមចំនួនដប់ប្រាំនាក់មកកាន់មន្ទីរស-២១ចំនួនពីរដងដែរ ។ លើសពីនេះ "អ្នកនាំសារនៅក្នុងទីក្រុង" ក៏បាននាំយកអ្នករស់នៅបរទេសមកកាន់មន្ទីរស-២១ តាមរយៈការបោកបញ្ឆោតរបស់ពួកគេផងដែរ ។ ដូច្នេះអង្គភាពរបស់ ហ៊ីម ហ៊ុយ ក៏មានតួនាទីចាប់ខ្លួនអ្នកទោសដែលមកពីបរទេសដែរ ។

នៅពេលមនុស្សដែលត្រូវបានចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរស-២១ អ្នកទាំងនោះត្រូវបានដាក់ខ្នោះដៃខ្នោះជើង ចងភ្នែក និងឲ្យអង្គុយនៅលើរថយន្តមួយ ។ អ្នកទោសមិនអនុញ្ញាតឲ្យធ្វើចលនាតាមអំពើចិត្តទេ ពីព្រោះថា ការធ្វើដូច្នេះអាចបង្កើនឲ្យមានឱកាសរត់គេចខ្លួនកាន់តែច្រើន ។ ការធ្វើដំណើរនៅក្នុងប្រទេសតម្រូវឲ្យមានសំបុត្រអនុញ្ញាត ហើយមានម្តងនោះ ហ៊ីម ហ៊ុយ ក៏ទទួលបានសំបុត្រអនុញ្ញាតឲ្យធ្វើដំណើរពី ហ៊ា ដែលមានចុះហត្ថលេខាដោយ សុន សេន ដែលជាប្រធានរបស់ ឌុច ផងដែរ ។

ក្រោយពីបានមកដល់មន្ទីរស-២១ហើយ អ្នកទោសគ្រប់រូបបានធ្វើដំណើរឆ្លងកាត់អគារតូចមួយដែលមានទីតាំងស្ថិតនៅខាងក្រៅរបងច្រកចូល ។ សម្រាប់អ្នកទោសដែលមិនទាន់បានចាប់ខ្លួន អង្គភាពរបស់ ហ៊ីម ហ៊ុយ នឹងនាំមកកាន់បន្ទប់ចាប់អ្នកទោស ដើម្បីឲ្យអ្នកទាំងនោះអង្គុយចុះនៅក្បែរតុមួយ រួចហើយក៏ចាប់ខ្លួនអ្នកទាំងនោះតែម្តង ។ ជួនកាលមានអ្នកទោសរហូតដល់ទៅហាសិប-ហុកសិបនាក់ បានមកកាន់មន្ទីរស-២១ក្នុងពេលតែមួយ ។ អ្នកទោសទាំងអស់ត្រូវចុះឈ្មោះនិងថតរូបដែលមានភ្ជាប់ជាមួយនឹងលេខសម្គាល់មុននឹងត្រូវបញ្ជូនទៅអង្គភាពមួយទៀត ដែលទទួលបន្ទុកខាងបែងចែកអ្នកទោសទៅតាមកម្រិតរបស់គេ រួចហើយក៏បញ្ជូនអ្នកទោសទាំងនោះទៅកាន់មន្ទីរឃុំឃាំងរៀងៗខ្លួន ។ ក្នុងដំណាក់កាលបែងចែងអ្នកទោសនេះ យ៉ាងហោចណាស់ក៏មានអ្នកទោសសំខាន់ខ្លះត្រូវបានបញ្ជូនទៅកាន់មន្ទីរកសាងខ្លួន ព្រៃស (មន្ទីរស-២៨) ជំនួសឲ្យមន្ទីរស-២១ដែរ ។

ស្តីពីស្ថានភាពឃុំឃាំងវិញ ហ៊ឹម ហ៊ុយ បានគូសបញ្ជាក់ថា អ្នកទោសត្រូវបានឆ្មាំយាមគុកបាញ់ទឹកសម្អាតខ្លួននឹងបំពង់ទុយយ៉ូក្នុងបន្ទប់ឃុំឃាំងតែម្តង ។ ការប្រើប្រាស់វិធីសាស្ត្របែបនេះ គឺធ្វើឡើងដើម្បីចៀសវាងកុំឲ្យអ្នកទោសមានឱកាសរត់គេចខ្លួន ។ ហ៊ឹម ហ៊ុយ បានរៀបរាប់បន្តទៀតថា របបអាហារមានលក្ខណៈមិនគ្រប់គ្រាន់ទេ ពីព្រោះថាអ្នកទោសម្នាក់ទទួលបានបបរតែមួយវែកកន្លះពីរដងក្នុងមួយថ្ងៃតែប៉ុណ្ណោះ ជាលទ្ធផលអ្នកទោសទាំងអស់មាន«រូបរាងស្គមស្គាំង» ។ ហ៊ឹម ហ៊ុយ បាននិយាយថា អ្នកទោសស្រីត្រូវបានចាត់ទុកថា ជាអ្នកទោសទន់ខ្សោយដែលមិនអាចប្រឆាំងតទល់ជាមួយនឹងឆ្មាំយាមគុក ហេតុដូច្នេះហើយអ្នកទោសស្រីទាំងនោះមិនត្រូវបានដាក់ខ្នោះទេ ហើយត្រូវបានដាក់ឲ្យនៅជាប់ឃុំឃាំងនៅក្នុងបន្ទប់ធំមួយដែលមានចាក់សោរបិទជិតជាមួយនឹងកូនៗរបស់គេ ។

ហ៊ឹម ហ៊ុយ មិនធ្លាប់បានឃើញការសួរចម្លើយឡើយ ប៉ុន្តែគាត់បានពន្យល់ថា អ្នកទោសទាំងអស់ត្រូវបានឃុំខ្លួន សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ ។ គាត់បាននិយាយថា អ្នកទោសជាច្រើនបានស្លាប់នៅក្នុងបន្ទប់ឃុំឃាំងរបស់គេដោយសារតែការរងរបួសធ្ងន់ធ្ងរក្រោយពីទទួលទារុណកម្ម ហើយសាកសពអ្នកទោសទាំងនោះត្រូវបានកប់នៅក្នុងបរិវេណមន្ទីរស-២១ជាបន្តបន្ទាប់ ។ អ្នកទោសដែលរស់រានមានជីវិតពីការធ្វើទារុណកម្មត្រូវបានសម្លាប់ក្នុងរយៈពេលមួយឬពីរសប្តាហ៍ បន្ទាប់ពីការសួរចម្លើយរបស់គេត្រូវបានបញ្ចប់ ។

យោងតាមសម្តីរបស់ ហ៊ឹម ហ៊ុយ បុគ្គលិកមន្ទីរស-២១ដែលត្រូវបានបោសសម្អាតអ្នកទោសសំខាន់ៗ ទាសករសង្គ្រាមជនជាតិវៀតណាម ជនជាតិបរទេស និងកូនក្មេងទាំងអស់ត្រូវបានសម្លាប់នៅក្បែរបរិវេណមន្ទីរស-២១ ជាជាងនៅជើងឯក ។ អ្នកទោសទាំងនោះត្រូវបាននាំចេញពីបន្ទប់ឃុំឃាំងរបស់គេម្តងមួយៗក្រោយពីត្រូវបានប្រាប់ថា ពួកគេត្រូវជន្លៀសឲ្យទៅរស់នៅផ្ទះថ្មី ។ តាមពិត អ្នកទោសទាំងនោះត្រូវបាននាំមកកាន់មាត់រណ្តៅ បន្ទាប់មកពួកគេត្រូវបានបង្ខំឲ្យលុតជង្គង់ ។ បន្ទាប់មកទៀតឆ្មាំយាមគុកវាយអ្នកទោសចំកញ្ចឹងកមុននឹងអារបំពង់កអ្នកទោសទាំងនោះ ។ អ្នកទោសត្រូវបានដោះសម្លៀកបំពាក់ចេញ និងរួមទាំងខ្នោះដៃជើងដែរដើម្បីទុកសម្រាប់ប្រើប្រាស់នាពេលក្រោយ ។ ចុងក្រោយបង្អស់ អ្នកទោសត្រូវបានរុញទម្លាក់ក្នុងរណ្តៅ ហើយកប់ភ្លាមៗតែម្តង ។

ហ៊ឹម ហ៊ុយ ក៏បានរៀបរាប់ពីសាកសពជនជាតិបរទេសដែលត្រូវបានដុតជាមួយនឹងសំបកកង់ឡាននៅលើផ្លូវជាតិក្រោយពីពួកគេត្រូវបានសម្លាប់នៅក្នុងមន្ទីរស-២១រួចមក ។ ហ៊ឹម ហ៊ុយ បាននិយាយថា

ឌុច និយាយត្រូវ ដែលថាមានជនជាតិវៀតណាមប្រមាណ៣៤៥នាក់ត្រូវបានឃុំឃាំងនៅមន្ទីរស-២១ ហើយ ហ៊ឹម ហ៊ុយ ក៏បានអះអាងថា ជនជាតិវៀតណាមទាំងអស់នោះត្រូវបានសម្លាប់នៅក្បែរបរិវេណមន្ទីរស-២១ ។ ហ៊ឹម ហ៊ុយ បានសន្និដ្ឋានថា កូនក្មេងប្រមាណហាសិបទៅហុកសិបនាក់ដែលមានអាយុចាប់ពីមួយឆ្នាំទៅប្រាំបីឆ្នាំក៏ត្រូវបានសម្លាប់នៅក្បែរបរិវេណមន្ទីរស-២១ដែរ ។

យោងតាមសម្តីរបស់ ឌុច គ្មានអ្នកទោសណាម្នាក់ត្រូវបានដោះលែងចេញពីមន្ទីរស-២១ឡើយ ។ ហ៊ឹម ហ៊ុយ ក៏បានយល់ស្របនឹងការអះអាងនេះ ប៉ុន្តែគាត់បាននិយាយថា មានម្តងនោះគាត់ធ្លាប់បានឃើញអ្នកទោសជនជាតិថៃមួយក្រុមត្រូវបានដោះលែងដោយមិនដឹងពីមូលហេតុ ។

ហ៊ឹម ហ៊ុយ បានពន្យល់ថា មានការបោសសម្អាតយ៉ាងតឹងរ៉ឹងលើបុគ្គលិករបស់មន្ទីរស-២១ ដោយមានការចាប់ខ្លួនបុគ្គលិករហូតដល់ទៅពីររយនាក់ក្នុងចំណោមបុគ្គលបួនរយនាក់ ។ បុគ្គលិកមន្ទីរស-២១ មួយភាគធំមកពីកងពល៧០៣ ។ ក្នុងឆ្នាំ១៩៧៧ កម្មាភិបាលកងពល៧០៣នៅឯសមរភូមិជាច្រើននាក់ត្រូវបានសួរចម្លើយ ហើយចម្លើយសារភាពរបស់កម្មាភិបាលទាំងនោះមានជាប់ពាក់ព័ន្ធនឹងអតីតមិត្តរួមការងាររបស់គេដែលបានក្លាយជាបុគ្គលិកមន្ទីរស-២១ ។ ហ៊ឹម ហ៊ុយ មិនបានដឹងពីបទល្មើសដែលបុគ្គលិកទាំងនោះត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនោះទេ ប៉ុន្តែគាត់គ្រាន់តែដឹងថា "មនុស្សជាច្រើនបានបាត់ខ្លួន" ។ ហ៊ឹម ហ៊ុយ បានបន្ថែមថា ឆ្មាំយាមគុកខ្លះដែលប្រព្រឹត្តខុសបន្តិចបន្តួចត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២៤ដើម្បីកសាងខ្លួន ។ គាត់បានពន្យល់ទៀតថា ដំបូងឡើយពេលបានចូលមកបំរើការនៅមន្ទីរស-២១ គាត់អាចដើរចុះឡើងបានគ្រប់ទីកន្លែង និងអាចជជែកលែងជាមួយនឹងមិត្តរួមការងារទៀតផង ។ ប៉ុន្តែ ក្រោយពីការបោសសម្អាតចាប់ផ្តើមកើតមានឡើង បុគ្គលិកទាំងអស់នាំគ្នាតាមដានគ្នាទៅវិញទៅមក ជាហេតុធ្វើឲ្យការសន្ទនា និងការដើរហើរកាន់តែមានសភាពតឹងរ៉ឹង ។

## វិធីសាស្ត្រសម្លាប់ដែលត្រូវបានអនុវត្តនៅវាលពិឃាតបឹងជើងឯក

ហ៊ឹម ហ៊ុយ បានផ្តល់សក្ខីកម្មដ៏លម្អិតទាក់ទិននឹងដំណើរប្រតិបត្តិការនៅវាលពិឃាតបឹងជើងឯករបស់ឌុច ។

ក្រោយពីទទួលបានបញ្ជីឈ្មោះអ្នកទោសពី ហ៊ី មក អន្តភាពរបស់ ហ៊ីម ហ៊ុយ ត្រូវនាំអ្នកទោសចេញពីបន្ទប់ឃុំឃាំងនៅម៉ោង៦:៣០នាទីល្ងាច ហើយបណ្តើរអ្នកទោសទាំងនោះទៅកាន់រថយន្តដែលមានដំបូលបិទជិតមួយ ។ អ្នកទោសទាំងអស់ត្រូវបានដាក់ខ្នោះ និងចងបិទភ្នែកក្នុងរយៈពេលធ្វើដំណើរសាមសិបនាទី ។ ដាក់ស្តែង អ្នកទោសទាំងនោះត្រូវបានប្រាប់ថា ពួកគេត្រូវបានផ្លាស់ទៅនៅផ្ទះថ្មី ។ ហ៊ីម ហ៊ុយ មានតួនាទីពិនិត្យមើលឈ្មោះអ្នកទោសពីហុកសិប ទៅមួយរយនាក់ដែលមាននៅក្នុងបញ្ជីមុននឹងរថយន្តដឹកអ្នកទោសទាំងនោះទៅកាន់វាលពិឃាតបឹងជើងឯក ។

ក្រោយពីការមកដល់របស់អ្នកទោស អន្តភាពនៅបឹងជើងឯកបានត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលអ្នកទោស ។ ដំបូង ឆ្មាំយាមគុកបានតំឡើងម៉ាស៊ីនភ្លើងដើម្បីបំភ្លឺអ្នកទោសនៅពេលដែលពួកគេកំពុងត្រូវបាននាំចេញពីរថយន្ត ។ អ្នកទោសទាំងនោះត្រូវបានបង្ខំឲ្យរង់ចាំនៅកន្លែងងងឹតក្រោមផ្ទះធំមួយខ្នង ។ ជាទូទៅ អ្នកទោសទាំងនោះត្រូវបាននាំចេញទៅកាន់រណ្តៅម្តងមួយៗ ហើយវិធីសាស្ត្រសម្លាប់នៅជើងឯកក៏ត្រូវបានអនុវត្តដូចគ្នានៅមន្ទីរស-២១ដែរ និយាយឲ្យចំ គឺវាយអ្នកទោសចំកញ្ចឹងក បន្ទាប់មកអារកអ្នកទោសទាំងនោះនឹងកាំបិត ។ បន្ថែមលើនេះ សម្លៀកបំពាក់និងខ្នោះដៃក៏ត្រូវបានដោះចេញ ។ ចុងក្រោយបង្អស់ អ្នកទោសត្រូវបានរុញទម្លាក់ក្នុងរណ្តៅហើយកប់ភ្លាមៗតែម្តង ។ ដោយសារតែភាពងងឹត និងទោសមានចំនួនច្រើន “ការសម្លាប់ត្រូវចំណាយពេលជាច្រើនម៉ោង” ដើម្បីសម្លាប់អ្នកទោសទាំងអស់ ជួនកាលការសម្លាប់ធ្វើឡើងរហូតដល់ម៉ោងពីរយប់ក៏មានដែរ ។ ក្នុងអំឡុងដំណើរការសម្លាប់ដ៏យូរនេះ មានអ្នកទោសម្នាក់បានរត់រួច ប៉ុន្តែអ្នកទោសនោះក៏ត្រូវបានចាប់ខ្លួនវិញ ។

ខុសពី ឌុច ដែលបាននិយាយថា ខ្លួនបានទៅមើលការសម្លាប់នៅជើងឯកតែម្តងក្រោយពីត្រូវបានបង្ខំដោយថ្នាក់លើរបស់ខ្លួននោះ ហ៊ីម ហ៊ុយ បាននិយាយថា ឌុច យ៉ាងហោចណាស់បានទៅជើងឯកពីរដងដែរ ។ ហើយមានម្តងនោះ ឌុច បាននៅត្រួតពិនិត្យការសម្លាប់នៅជើងឯករហូតដល់អ្នកទោសទាំងអស់ត្រូវបានសម្លាប់ ។ បើទោះបីជា ហ៊ីម ហ៊ុយ ធ្លាប់បានប្រាប់សហចៅក្រមស៊ើបអង្កេតកាលពីមុនថា ឌុច បានបង្រៀនគាត់ពីវិធីសាស្ត្រសម្លាប់ក៏ដោយ ក៏នៅក្នុងថ្ងៃនេះ ហ៊ីម ហ៊ុយ បែរជានិយាយថា ហ៊ី ទេដែលជាអ្នកបង្រៀនពីវិធីសាស្ត្រសម្លាប់អ្នកទោស ។ បន្ថែមលើនេះ ហ៊ីម ហ៊ុយ ធ្លាប់បានប្រាប់សហចៅក្រមស៊ើបអង្កេតថា មានម្តងនោះ ឌុច បានបញ្ជាឲ្យគាត់សម្លាប់បុរសម្នាក់ដោយផ្ទាល់ ។ ប៉ុន្តែជាថ្មីម្តងទៀត គាត់បែរជានិយាយថា គាត់មិនច្បាស់ថា តើ ឌុច ឬក៏ ហ៊ី ដែលបញ្ជាឲ្យគាត់សម្លាប់មនុស្ស ។ ប៉ុន្តែគាត់ច្បាស់ណាស់ថា ប្រសិនបើមិនមែន ឌុច ច្បាស់ជា ហ៊ី ជាមិនខាន ។ ដោយកត់

សម្គាល់ពីភាពប្រចូកប្របល់នៅក្នុងបន្ទប់សវនាការ ចៅក្រម ឡាវែន៍ បានស្នើសុំឲ្យ ឌុច ក្រោកឈរ ហើយបានសួរទៅកាន់ ហ៊ឹម ហ៊ុយ ថា «តើបុគ្គលនេះជានរណា?» បន្ទាប់មកទៀត លោកចៅក្រម បានសួរបញ្ជាក់ម្តងទៀតថា នេះ(ឌុច)គឺជា ឌុច ដែលបញ្ជាឲ្យគាត់សម្លាប់អ្នកទោសម្នាក់មែនដែរឬទេ? ហ៊ឹម ហ៊ុយ បានព្យាយាមពន្យល់ពីការយល់ច្រឡំរបស់គាត់ថា ដោយសារតែនៅជើងឯកងងឹតពេកទើបគាត់មិនអាចចំណាំថា នរណាឲ្យពិតប្រាកដ ។ លើសពីនេះ ឆ្មាំយាមគុកម្នាក់ៗត្រូវតែប្រញាប់សម្លាប់អ្នកទោសទាំងអស់មុននឹងមេឃភ្លឺ ។

## មន្ទីរស-២៤

នៅចុងឆ្នាំ១៩៧៨ ហ៊ឹម ហ៊ុយ ត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២៤ជាមួយនឹងមនុស្សប្រុសពីរក្រុម ដើម្បីទៅដកស្ទូង ជីកប្រឡាយ និងស្ថាបនាប្រឡាយទឹក ។ យោងតាមសក្ខីកម្មដ៏ខ្លីរបស់ ហ៊ឹម ហ៊ុយ វាមានលក្ខណៈមិនច្បាស់លាស់នៅឡើយថា តើគាត់ត្រូវបានឃុំឃាំងនៅមន្ទីរស-២៤ជាអ្នកទោស ឬគ្រាន់តែត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅទីនោះ? ហ៊ឹម ហ៊ុយ បានអះអាងថា តាមធម្មតាគាត់ដេកនៅក្នុងបន្ទប់មួយដែលគ្មានចាក់សោរទេ ។ ហ៊ឹម ហ៊ុយ មិនដឹងពីមូលហេតុដែលគាត់ត្រូវបានបញ្ជូនមកមន្ទីរស-២៤ឡើយ ។ ហ៊ឹម ហ៊ុយ បាននៅមន្ទីរស-២៤រហូតដល់កងទ័ពវៀតណាមវាយបានទីក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩ ។

## វិធានការការពារខ្លួនត្រូវបានជំទាស់មិនឲ្យអនុវត្ត

អង្គជំនុំជម្រះសាលាដំបូងបានប្រកាសជំទាស់នឹងការស្នើសុំវិធានការការពារខ្លួនរបស់សាក្សី KW10 ។

អង្គភាពគាំទ្រអ្នកជំនាញនិងសាក្សី បានផ្តល់របាយការណ៍វាយតម្លៃដែលស្តីពីហានិភ័យសម្ងាត់មួយជូនដល់ចៅក្រម ព្រមទាំងបានសម្រេចមិនអនុញ្ញាតឲ្យមានការអនុវត្តវិធានការការពារខ្លួនចំពោះសាក្សី KW10 ទេ ពីព្រោះថាសាក្សីរូបនេះដែលជាអតីតអ្នកសួរចម្លើយឲ្យមន្ទីរស-២១ត្រូវបានសាធារណជនជាច្រើនស្គាល់ និងអាចត្រូវបានស្គាល់ពីអត្តសញ្ញាណរួចជាមុនទៅហើយ បើទោះបីជាសាក្សីរូបនេះធ្វើសក្ខីកម្មដោយសម្ងាត់ក៏ដោយ ។ ចៅក្រមបានយល់ស្របនឹងអង្គភាពគាំទ្រអ្នកជំនាញនិងសាក្សី ដោយធ្វើការកត់សម្គាល់ថា មានមនុស្សជាច្រើននាក់បានស្គាល់សាក្សី KW10 ហេតុដូច្នេះការអនុវត្តវិធាន

ការការពារខ្លួនអាចនឹងមិនមានប្រសិទ្ធិភាព ។ លើសពីនេះ ក្រុមគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់សាក្សីរូបនេះ បានដឹងពីប្រវត្តិរូបរបស់សាក្សីរួចហើយដែរ ។

យោងតាមវិធានផ្ទៃក្នុងទី២៩ ក្រោយពីមានការស្នើសុំ ចៅក្រមនឹងសម្រេចឲ្យប្រើប្រាស់វិធានការការពារខ្លួនដើម្បីការពារសាក្សី "ដោយសារតែការបង្ហាញខ្លួនក្នុងតុលាការរបស់សាក្សីនោះអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិត ឬសុខភាពរបស់សាក្សី ឬក៏បណ្តាលឲ្យសមាជិកគ្រួសារ ឬសាច់ញាតិជិតស្និទ្ធិរបស់សាក្សីប្រឈមមុខនឹងគ្រោះថ្នាក់" ។ វិធាននេះ បានផ្តល់ជាវិធានការមួយចំនួនដូចជាដំណើរការនីតិវិធីដោយសម្ងាត់ ការប្រើប្រាស់ឈ្មោះក្លែងក្លាយ និងការមិនចាក់ផ្សាយសម្លេង ឬបង្ហាញខ្លួនរបស់សាក្សី ។